ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សេចក្តីជូនដំណឹង

## ស្តីពីការដេញថ្លៃការងារសាងសង់ផ្លូវក្រាលគ្រួសក្រហម និងផ្លូវបេតុង ដែលមានទីតាំងស្ថិតក្នុងដីសម្បទានសង្គមកិច្ច ក្នុងឃុំពង្រ ស្រុកចុងកាល ខេត្តឧត្តរមានជ័យ

**Construction of Laterite & Concrete Roads in Pong Ro SLC, Chong Kal District, Oddar Meanchey Province**
**Contract No.: MLMUPC-W-29**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣ (LASED III) នឹងធ្វើការដេញថ្លៃការងារសាងសង់ផ្លូវក្រាលគ្រួសក្រហម និងផ្លូវបេតុង ដែលមានទីតាំងស្ថិតក្នុងដីសម្បទានសង្គមកិច្ច ក្នុងឃុំពង្រ ស្រុកចុងកាល ខេត្តឧត្តរមានជ័យ។

គោលបំណងរបស់គម្រោង គឺដើម្បីផ្តល់កម្មសិទ្ធិកាន់កាប់ដីធ្លី ការអភិវឌ្ឍកសិកម្ម សេវាសង្គម និងហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងលើកកម្ពស់ជីវភាពរស់នៅរបស់កសិករខ្នាតតូចក្នុងសហគមន៍ និងសម្បទានដីសង្គមកិច្ចរបស់គម្រោងក៏ដូចជាដើម្បីធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំនៅក្នុងប្រទេសកម្ពុជា។ គម្រោង LASED III បានទទួលហិរញ្ញប្បទានពីធនាគារពិភពលោក ដើម្បីគាំទ្រសកម្មភាពទាំងឡាយដែលរួមមាន ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រខ្នាតតូចរបស់គម្រោង LASED II និង LASED III និងផ្តល់ការអភិវឌ្ឍលើសម្បទានដីសង្គមកិច្ចចំនួន ១០ ទីតាំង, សហគមន៍ដែលបានចុះបញ្ជីដីចំនួន ៣៣ សហគមន៍, សហគមន៍ងាយរងគ្រោះនៅតំបន់ឆ្នេរចំនួន ១២ សហគមន៍ និងការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំចំនួន ១៥០ឃុំ។

អាស្រ័យហេតុនេះ ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ចូលរួមដេញថ្លៃ សូមអញ្ជើញទំនាក់ទំនងមកគម្រោង LASED III បន្ទប់លេខ ៧០៨ អគារទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតាមរយៈអ៊ីម៉ែល **លោក ឫទ្ធី រតនៈជ័យសិទ្ធិ** នាយកប្រតិបត្តិការគម្រោង rrcheyseth@gmail.com និងត្រូវចម្លងជូន khieu.borin808@gmail.com vichiet.him@gmail.com u.nareth89@gmail.com និង proc.lasediii@gmail.com។

កាលបរិច្ឆេទដាក់ឯកសារដេញថ្លៃត្រឹមថ្ងៃទី២៧ **ខែ** សីហា **ឆ្នាំ២០២៦ ម៉ោង ១៤:៣០** រសៀល។

ថ្ងៃសុក្រ ១០កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ២០២៦